ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ...សហវ...

ថ្ងៃ ... ខែ ... ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០២០

ប្រកាស
ស្តីពី
ការផ្ទេរឥណទានថវិកា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃសុក្រ ១១កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃអង្គារ ១៥កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមដំណាក់នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- បានឃើញអនុក្រឹត្យលេខ ២១៨ អនក្រ.បក ចុះថ្ងៃអង្គារ ១៥កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីការផ្ទេរឥណទានថវិកា
- តាមការចាំបាច់ដើម្បីអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១

សម្រេច

ប្រការ១ .-

ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ នូវការផ្ទេរឥណទានថវិកាដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម៖

និយ័តកម្មចេញពី ៩៩ (ចំណាយមិនទាន់បែងចែកមានមុខសញ្ញា)

ឯកតា៖ លានរៀល

ជំពូក	គណនី	អនុគណនី	បរិយាយ	ច្បាប់ហិរ. ឆ្នាំ ២០២១	ឥណទានមុននិយ័តកម្ម	និយ័តកម្ម		ឥណទានថ្មីក្រោយនិយ័តកម្ម
						កើន	ថយ	
			<u>និយ័តកម្មចេញ</u>				**<u>4.893.586</u>**	
			៩៩-ចំណាយមិនទាន់បែងចែកមានមុខសញ្ញា				**4.893.586**	
66			បន្ទុកហិរញ្ញវត្ថុ	621.360	621.360	-	621.360	0
65			ឧបត្ថម្ភរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់	1.060.450	1.060.450	-	1.060.450	0
65			ការប្រគល់មុខងារអប់រំ និងសុខាភិបាល	824.081	824.081	-	824.081	0
69	6901	69011	ចំណាយមិនបានគ្រោងទុក	647.000	647.000	-	1.300	645.700
50			មានមុខសញ្ញាច្បាស់លាស់ ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល	1.185.190	1.185.190	-	1.185.190	0
26			ការវិនិយោគ	1.112.105	1.112.105	-	1.112.105	0
27			អចលកម្មហិរញ្ញវត្ថុផ្សេងៗ	89.100	89.100	-	89.100	0
			<u>និយ័តកម្មចូល</u>			**<u>4.893.586</u>**		
			១០-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ			**4.893.586**		
66			បន្ទុកហិរញ្ញវត្ថុ	-	-	621.360	-	621.360
65	6501	65011	ឧបត្ថម្ភធនដល់រាជធានី-ខេត្ត	-	-	14.106,6	-	14.106,6
65	6501	65012	ឧបត្ថម្ភធនដល់ក្រុង-ស្រុក-ខណ្ឌ	-	-	338.095,4	-	338.095,4
65	6501	65013	ឧបត្ថម្ភធនដល់ឃុំ-សង្កាត់	-	-	709.548	-	709.548
65	6501	65016	ឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ	-	-	824.081	-	824.081
50			ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល	-	-	1.185.190	-	1.185.190
26	2601	26012	ការវិនិយោគទុនរួមគ្នា	-	-	1.112.105	-	1.112.105
27	2701	27011	ការឱ្យខ្ចីទៅសហគ្រាសសាធារណៈ	-	-	89.100	-	89.100

ប្រការ២ .–

ឥណទានថវិកាដែលបានផ្ទេរក្នុងប្រការ ១ ខាងលើនេះ ត្រូវបានអនុញ្ញាតឱ្យបំពេញបន្ថែមទៅក្នុងសៀវភៅថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១។

ប្រការ៣ .–

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ចម្លងជូន៖
- អគ្គនាយកដ្ឋានរតនាគារជាតិ
- អគ្គនាយកដ្ឋាន/នាយកដ្ឋានពាក់ព័ន្ធ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ